# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៣៦៧ ព្រទ-២០០១

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកប្រធានតុលាការខេត្ត ក្រុង**

**លោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**

**កម្មវត្ថុ:** អំពីការឃុំខ្លួនពិរុទ្ធជនលើសថេរវេលាកំណត់នៃច្បាប់ ។

**យោង:** លិខិតលេខ១៧៩.០២គ.ស.ម.ក.ចុះថ្ងៃទី០៣-០៩-២០០១ របស់គណៈកម្មាធិការការពារសិទ្ធិមនុស្សកម្ពុជា

ខ្ញុំសូមជម្រាបអស់លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ថា គណៈកម្មាធិការការពារសិទ្ធិមនុស្សកម្ពុជាបានសង្កេតឃើញថា បច្ចុប្បន្នមានពិរុទ្ធជនមួយចំនួនដែលកំពុងជាប់ឃុំជាបណ្តោះអាសន្នលើសថេរវេលាកំណត់នៃច្បាប់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា នៅមិនទាន់បានទទួលការវិនិច្ឆ័យទោសនៅឡើយ គណៈកម្មាធិការនេះបានសំណូមពរឱ្យក្រសួងយុត្តិធម៌ជួយជំរុញដល់តុលាការខេត្ត-ក្រុង ឱ្យលើកយកករណីឃុំខ្លួនពិរុទ្ធជនលើសថេរវេលានេះមកចាត់ការដាក់ជំនុំជម្រះឱ្យបានឆាប់ និងទប់ស្កាត់កុំឱ្យបាតុភាពនេះកើតមានបន្តទៅទៀត ពាក់ព័ន្ធនឹងការឃុំខ្លួនលើសកំណត់ច្បាប់នេះ សេចក្តីសម្រេចនៃសន្និបាតុការងារយុត្តិធម៌ ឆ្នាំ២០០០ របស់ក្រសួងយុត្តិធម៌ចំណុច II ធំ អំពីបញ្ហារយៈពេលនៃការឃុំខ្លួនតាមច្បាប់កំណត់ បានកំណត់អំពីផែនការនិងវិធានការនេះសព្វគ្រប់អស់ហើយ។

ដូច្នេះសូមលោកប្រធានតុលាការ លោកព្រះរាជអាជ្ញា ចាត់វិធានការឱ្យមន្ត្រីក្រោមឱវាទកំណត់ពេលវេលាសមស្របធ្វើយ៉ាងណាឱ្យស្ថាប័នអយ្យការ និងតុលាការសហការគ្នាល្អក្នុងការដោះស្រាយរឿងក្តី ជៀសវាងការឃុំខ្លួនជនត្រូវចោទលើសកំណត់ច្បាប់ ។ ករណីអស់លោកជួបការលំបាកមិនអាចដោះស្រាយបានសូមរាយការណ៍ជូនក្រសួងយុត្តិធម៌ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាបន្ទាន់(មាត្រា៥៥ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ) ។

ទទួលបានសេចក្តីណែនាំនេះ សូមលោកប្រធានតុលាការ លោកព្រះរាជអាជ្ញាជួយផ្សព្វផ្សាយដល់មន្ត្រីក្រោមឱវាទឱ្យយកស្មារតីទទួលខុសត្រូវខ្ពស់ បំពេញតាមតួនាទីរៀងៗខ្លួនដែលច្បាប់ប្រគល់ឱ្យដោយគោរពថេរវេលាដែលមានកំណត់ក្នុងច្បាប់ ឬ សារាចរផ្សេងៗរបស់ក្រសួងជៀសវាងការចោទប្រកាន់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ។

សូមលោកប្រធានតុលាការ លោកព្រះរាជអាជ្ញាទទួលនូវការស្រលាញ់រាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១

**រដ្ឋមន្ត្រី**

**អ៊ុក វិធុន**

ចម្លងជូន
-តុលាការកំពូល
-សាលាឧទ្ធរណ៍
-គណៈកម្មាធិការ ការពារសិទ្ធិមនុស្សកម្ពុជា
-ដើម្បីជ្រាប